00272405 E9

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Suy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier Nº 001/18-07-2007-ECCC/TC

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Suy

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ | ២២ ខែ មករា ឆ្នាំ ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ: |

# សេចក្តីណែនាំស្តីពីកាលបរិច្ឆេទចុងក្រោយ

# សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំវិធានការការពារ និង ភាគីដែលមានបំណងលើកករណីអញ្ញត្រកម្ម

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ

François ROUX

០០១/១៨-០៧-២០០៧-អវតក/អជសង

Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រ៊ីនណា
Pierre Olivier SUR

**យើងចៅក្រម និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

**អនុលោមតាម** បទប្បញ្ញត្តិនៃវិធាន ២៩ និង ៨៩ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធាន”)។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ (“សេចក្តីសម្រេច”)

**បានឃើញ**សេចក្តីសម្រេចខាងលើចោទប្រកាន់លើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ភេទប្រុស ជាតិខ្មែរ កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដោយបញ្ជូនឈ្មោះនេះមកជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីបទ៖ បទល្មើសប្រឆាំងមនុស្សជាតិ អំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

**ដោយយល់ច្បាស់ថា** តាមបទប្បញ្ញត្តិមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថាសវនាការប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។

**ហេតុដូច្នេះសូមណែនាំ:**

១. រាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបំណងស្នើសុំវិធានការការពារ ស្របតាមវិធាន ២៩ នៃវិធានផ្ទៃក្នុងនៅក្នុងដំណាក់កាលជំនុំជម្រះ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ អនុលោមតាមមាត្រា២.១នៃសេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ អោយបានឆាប់រហ័សយ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០៩ ម៉ោង ១៦:០០ នាទី

២. រាល់ភាគីនៃដំណើរការនីតិវិធី ដែលមានបំណងលើកឡើងនូវករណីអញ្ញត្រកម្មនានាស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ត្រូវដាក់នូវខ្លឹមសារសំខាន់ៗសម្រាប់ការតវ៉ានូវករណីអញ្ញត្រកម្មនោះអោយបានឆាប់រហ័ស យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែ មករា ឆ្នាំ២០០៨ ម៉ោង ១៦:០០ នាទី ។ ខ្លឹមសារសំខាន់ៗនេះមិនត្រូវអោយលើសពី៤ទំព័រ ចំពោះភាសា ខ្មែរ និង ២ ទំព័រ ចំពោះភាសាអង់គ្លេស ឬ ភាសាបារាំង។

៣. រាល់អ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនទាន់បានដាក់ពាក្យសុំរួចរាល់ ហើយមានបំណងស្នើសុំវិធានការការពារនិងមានបំណងលើកឡើងនូវអញ្ញត្រកម្មណាមួយនោះ ត្រូវដាក់ពាក្យសុំនូវវិធានការការពារនិងខ្លឹមសារសំខាន់ៗនៃអញ្ញត្រកម្មនោះអោយបានឆាប់រហ័សយ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០៨ ម៉ោង ១៦:០០ នាទី ។ ខ្លឹមសារសំខាន់ៗនេះមិនត្រូវអោយលើសពី ៤ ទំព័រ ចំពោះភាសាខ្មែរ និង ២ទំព័រចំពោះភាសាអង់គ្លេស ឬ ភាសាបារាំង។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

និល ណុន